# ការទទួលខុសត្រូវរបស់អ្នកទទួលជំនួយនៅក្នុងកម្មវិធីសេវាការមើលថែទាំក្នុងផ្ទះ (IHSS) ដើម្បីបញ្ឈប់ការរុកគួនផ្លូវភេទលើស្ត្រីនៅកន្លែងធ្វើការ

ក្នុងនាមជានិយោជកនៃ IHSS, វាគឺជាការទទួលខុសត្រូវរបស់អ្នកក្នុងការរក្សាសុវត្ថិភាពនៅកន្លែងធ្វើការ ។ អ្នកអាចត្រូវបានប្តឹងដោយអ្នកផ្តល់សេវា/និយោជិករបស់អ្នក ប្រសិនបើ អ្នកអនុញ្ញាតឱ្យមានការរុកគួនផ្លូវភេទកើតឡើងនៅកន្លែងធ្វើការ ។

## តើការរុកគួនផ្លូវភេទគឺជាអ្វី?

ការរុកគួនផ្លូវភេទ មានពីរប្រភេទ:

"Quid pro quo" (ពាក្យឡាតាំងមានន័យថា "អោយអ្វីម្យ៉ាងដើម្បីបានអ្វីម្យ៉ាងមកវិញ") ការរុកគួនផ្លូវភេទ គឺនៅពេលដែលនរណាម្នាក់បានធ្វើឱ្យនិយោជិកផ្តល់ ឬយល់ព្រមផ្លូវភេទជាមុន ឬ អាកប្បកិរិយាផ្លូវភេទផ្សេងៗទៀតដើម្បីទទួលបាន ឬរក្សាការងារ ឬ ទទួលបានផលប្រយោជន៍ការងារដទៃទៀតណាមួយ ។

ការរុកគួនផ្លូវភេទនៃ "បរិយាកាសនៃកន្លែងធ្វើការដែលប្រកបដោយអរិយភាព" កើតឡើងនៅពេលណាដែលមានយោបល់មិនស្វាគមន៍ ឬ អាកប្បកិរិយាផ្អែកទៅខាងផ្លូវភេទ ធ្វើឱ្យរំខានដល់ការងាររបស់និយោជិក ឬ បង្កើតបរិយាកាសនៅកន្លែងធ្វើការ ដែលធ្វើឱ្យនិយោជិកខ្វាយខ្វល់ មិនរាក់ទាក់នឹងអ្នកដទៃ និងរកាំចិត្ត ។ និយោជិកអាចជួបប្រទះការរុកគួនផ្លូវភេទ សូម្បីតែការប្រព្រឹត្តដែលឥតគួរសមនិងមិនស្វាគមន៍ មិនត្រូវបានសំដៅចំពោះរូបគេដោយផ្ទាល់ក៏ដោយ ។

អាកប្បកិរិយានៃការរុកគួនផ្លូវភេទ រួមមានទាំង ប៉ុន្តែមិនបានកំណត់ចំពោះ:

- ការចាប់អារម្មណ៍ផ្លូវភេទដែលមិនចង់បាន
- ការផ្តល់អត្ថប្រយោជន៍ជាថ្នូរលំអៀងទៅផ្លូវភេទ
- ការគំរាមឱ្យធ្វើអ្វីមួយដើម្បីធ្វើឱ្យរួចគ្នាជាមួយនឹងបុគ្គល បន្ទាប់ពីបានទទួលការឆ្លើយតបដែលបដិសេធការចាប់អារម្មណ៍ផ្លូវភេទ
- ការសម្លឹងមិនដាក់ភ្នែក ដែលធ្វើឱ្យបុគ្គលដែលកំពុងមើលមកចំ មិនមានអារម្មណ៍សុខស្រួលឡើយ ការធ្វើចលនាផ្លូវភេទជាមួយរាងកាយ ឬ ការបង្ហាញវត្ថុបំណាង រូបភាព គំនូររូបតុក្កតា ឬ ផ្ទាំងរូបភាពដែលធ្វើឱ្យបុគ្គលនឹកគិតអំពីផ្លូវភេទ
- ការពោលពាក្យប្រមាថ ដែលធ្វើឱ្យអាម៉ាស់មុខ ឬការនិយាយពាក្យមិនសមរម្យអំពីផ្លូវភេទ
- ការហៅឈ្មោះឥតគួរសម ការពោលពាក្យបង្អាច់បង្អួច ឬ ការចំអកលលេង ដែលទាក់ទងនឹងផ្លូវភេទ
- ការប្រើពាក្យសម្តី យោបល់ សារទំនាក់ទំនងផ្លូវភេទ ឬការអញ្ជើញ ដែលធ្វើអោយបុគ្គលមានអារម្មណ៍ខ្វាយខ្វល់
- ការប៉ះពាល់ ឬការបំពារបំពានលើរាងកាយដែលមិនចង់បាន ឬ
- ការទប់ ឬការរាំងផ្លូវបុគ្គលមិនឱ្យធ្វើដំណើរទៅមុខ

ការរុកគួនមិនចាំបាច់មានលក្ខណៈទៅខាងផ្លូវភេទនោះទេ ហើយអាចមានរួមទាំង ការនិយាយពាក្យមិនគួរសមនិងដែលធ្វើឱ្យមានការឈឺចាប់ ទាក់ទងនឹងអង្គភេទ ឬភេទរបស់បុគ្គល ។ ឧទាហរណ៍ វាគឺជាការខុសច្បាប់ក្នុងការរុកគួនស្រ្តីភេទ ដោយការនិយាយអធិប្បាយនូវពាក្យមិនសមរម្យអំពីស្រ្តីភេទទូទៅ ។

ទាំងជនរងគ្រោះនិងអ្នករុកគួន អាចជាស្រ្តី ឬក៏បុរស ហើយជនរងគ្រោះនិងអ្នករុកគួន អាចនឹងមានអង្គភេទ/ភេទដូចគ្នា ។

## តើខ្ញុំអាចជៀសវាងការរុកគួនផ្លូវភេទនៅកន្លែងធ្វើការដោយរបៀបណា?

ក្នុងនាមជានិយោជកនៃ IHSS អ្នកត្រូវធ្វើគ្រប់យ៉ាងទាំងអស់ដែលអ្នកអាចធ្វើបាន ដើម្បីឱ្យកន្លែងធ្វើការ (ផ្ទះរបស់អ្នក) រួចផុតពីការរុកគួនផ្លូវភេទ ។ នៅទីនេះគឺជាគន្លឹះសំខាន់ៗមួយចំនួនដែលអ្នកអាចប្រើ ដើម្បីធានាធ្វើឱ្យបានប្រាកដថា អ្នក ឬនរណាម្នាក់នៅក្នុងផ្ទះរបស់អ្នក គឺមិនធ្វើការរុកគួនដល់អ្នកផ្តល់សេវា/និយោជិករបស់អ្នកឡើយ ។

<u>សេចក្តីសង្កេត</u>

- ត្រូវយល់ច្បាស់អំពីអាកប្បកិរិយា ឬឧប្បត្តិហេតុនៃការរុកគួនផ្លូវភេទ និងកុំធ្វើអ្វីវា
- ត្រូវមានការយល់ដឹងរហ័សចំពោះបុគ្គលដែលអាចមានការរកាំចិត្ត ដោយអាកប្បកិរិយាពាក្យសំដី និងដែលមិនបាននិយាយរបស់អ្នកឯទៀត ។
- ត្រូវយល់ច្បាស់នូវទម្រង់នៃការរុកគួនផ្លូវភេទ ដែលមិនងាយកត់សម្គាល់ដូចជា ការសម្លឹងមិនដាក់ភ្នែក ឬ ការប៉ះពាល់ដែលមិនចាំបាច់ និង
- ត្រូវប្រយ័ត្ននឹងវិធីឬរបៀបដែលអ្នកឯទៀតនៅក្នុងផ្ទះ ធ្វើ/ប្រព្រឹត្ត ហើយ មិនត្រូវធ្វើអ្វីដែលអាចជះឥទ្ធិពលជាអវិជ្ជមានទៅលើវិធីឬរបៀប ដែលអ្នកប្រាស្រ័យទាក់ទងជាមួយអ្នកឯទៀតឡើយ ។

<u>ការពិនិត្យមើល</u>

- យកចិត្តទុកដាក់ទៅលើការឆ្លើយតបរបស់អ្នកឯទៀត ដើម្បីជៀសវាងធ្វើអ្វីមួយដោយអចេតនា ដែលនឹងធ្វើឱ្យពួកគេមានការរកាំចិត្ត ។
- មិនត្រូវគិតដោយស្វ័យប្រវត្តិថា នរណាម្នាក់នឹងសប្បាយរីករាយ ឬ ចង់ឮការនិយាយកំប្លែងលេង ឬការនិយាយអធិប្បាយទាក់ទងនឹងផ្លូវភេទនៃអាការៈខាងក្រៅរបស់ពួកគេនោះ ។
- មិនត្រូវគិតដោយស្វ័យប្រវត្តិថា នរណាម្នាក់នឹងសប្បាយរីករាយ ឬ ចង់ឱ្យប៉ះពាល់ សម្លឹងមិនដាក់ភ្នែក ចែចង់ជាមួយ សុំដើរលេងជាមួយ ឬសុំទាក់ទងក្នុងចំណងផ្លូវភេទនោះ ។
- ត្រូវសួរខ្លួនអ្នកថា ប្រសិនបើអ្នកនឹងនិយាយ ឬនឹងធ្វើអ្វីមួយ តើអាចនឹងមានផលជាអវិជ្ជមានទៅលើអារម្មណ៍របស់អ្នកឯទៀតដែរឬទេ ។
- ពិនិត្យមើលអាកប្បកិរិយា ភាសាកាយវិការ និង យោបល់របស់អ្នក ។ សួរខ្លួនឯងថា "តើខ្ញុំអាចនឹងធ្វើឱ្យកម្រើកឡើងនូវអារម្មណ៍ផ្លូវភេទ ឬ ការសន្ទនាណាមួយដោយមិនដឹងខ្លួន ដោយវិធីដែលខ្ញុំប្រាស្រ័យទាក់ទងនឹងអ្នកឯទៀតដែរឬទេ?"
- កុំគិតថាការរុកគួនផ្លូវភេទមិនសំខាន់ ។ ប្រសិនបើអ្នកគិតថា អ្នកផ្តល់សេវា/និយោជិករបស់អ្នកនឹងត្រូវទទួលការរុកគួនផ្លូវភេទដោយបុគ្គលណាមួយ ឬក្រុមណាមួយ មិនត្រូវយកវាជាការលេងសើចឡើយ ។ កុំលើកទឹកចិត្តអ្នករុកគួនផ្លូវភេទដោយសើចញញឹម ឬអស់សំណើចនឹងការកំប្លែងលេងរបស់គាត់/នាង

នោះ ។ ត្រូវឱ្យអ្នករុកគួនដឹងថា អាកប្បកិរិយារបស់គេ មិនអាចទទួលយកបានឡើយ ។ ប្រសិនបើ អាកប្បកិរិយានេះនៅតែមានជាបន្ត ត្រូវតែធ្វើឱ្យបានប្រាកដក្នុងការហាមមិនឱ្យអ្នករុកគួនផ្លូវភេទចូល មកកន្លែងធ្វើការ (ផ្ទះ) នៅពេលដែលអ្នកផ្តល់សេវា/និយោជិក មានវត្តមាន ។

## តើខ្ញុំត្រូវធ្វើដូចម្តេច ប្រសិនបើ ការរុកគួនផ្លូវភេទត្រូវបានកើតឡើងនៅកន្លែងធ្វើការ (ផ្ទះរបស់ខ្ញុំ) ?

<u>ដំណោះស្រាយ</u>

- ផ្លាស់ប្តូរអាកប្បកិរិយារបស់អ្នក ឬ ប្រាប់ទៅអ្នករុកគួនថាអាកប្បកិរិយារបស់គេ ធ្វើឱ្យរំខានដល់អ្នកនិង ធ្វើឱ្យអ្នក មិនមានអារម្មណ៍សុខស្រួលឡើយ ។
- បញ្ឈាក់អំពីដំណើរប្រព្រឹត្តរបស់អ្នក ឬ ប្រាប់ទៅអ្នករុកគួនថាអាកប្បកិរិយាមួយណា (កាយវិការ រូបរាង ឬ ពាក្យសំដី) ដែលធ្វើឱ្យអ្នករកាំចិត្ត ។
- បញ្ឈប់ការរុកគួនផ្លូវភេទភ្លាមៗ ។ ក្នុងនាមជានិយោជកនៃ IHSS, វាគឺជាការទទួលខុសត្រូវរបស់អ្នក ក្នុងការរក្សាសុវត្ថិភាពនៅកន្លែងធ្វើការ ។
- អ្នកអាចត្រូវបានប្តឹងដោយអ្នកផ្តល់សេវា/និយោជិករបស់អ្នក ប្រសិនបើ អ្នកអនុញ្ញាតឱ្យមានការរុកគួន ផ្លូវភេទកើតឡើងនៅកន្លែងធ្វើការ ។
- ការរុកគួនផ្លូវភេទជាបន្តដោយរូបអ្នក ជានិយោជក ដោយបុគ្គលណាម្នាក់ផ្សេងទៀត ឬ ក្រុមណាមួយ អាចនឹងបណ្តាលឱ្យអ្នកផ្តល់សេវារបស់អ្នក ឈប់ធ្វើការ និង លែងធ្វើការឱ្យអ្នកតទៅទៀត ។
- ការរុកគួនផ្លូវភេទជាបន្តដោយរូបអ្នក ជានិយោជក ដោយបុគ្គលណាម្នាក់ផ្សេងទៀត ឬ ក្រុមណាមួយ អាចនឹងបណ្តាលឱ្យមានការជាប់ទាក់ទងនឹង ក្រសួងការងារនិងលំនៅដ្ឋានដោយយុត្តិធម៌ (DFEH) ឬ អាជ្ញាធរមានសមត្ថកិច្ចប្រចាំតំបន់ ប្រសិនបើ អ្នកផ្តល់សេវានោះមានអារម្មណ៍ថា គេអាចនឹងមានគ្រោះ ថ្នាក់ ឬ ប្រឈមនឹងហានិភ័យ ។
- សម្រាប់ព័ត៌មានបន្ថែមអំពីការការពារការរុកគួនផ្លូវភេទ សូមចូលទៅមើលនៅគេហទំព័ររបស់ DFEH នៅអាសយដ្ឋាន: www.dfeh.ca.gov/resources/frequently-asked-questions/employment-faqs/sexual-harassment-faqs/